**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*********

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**
គណៈកម្មាធិការលទ្ធកម្ម
លេខ ៖ ០០៣ អល.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃផ្គត់ផ្គង់សម្ភារៈបោះពុម្ព និងវេចខ្ចប់ (ទិញលើកទី១)

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថាៈ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់**សម្ភារៈបោះពុម្ពនិងវេចខ្ចប់** (ទិញលើកទី១)។

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ បានរៀបចំឯកសារសំរាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្ម អាសយដ្ឋានអគារលេខ ១៥៨ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ចាប់ពីថ្ងៃសុក្រ **១២ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២** ត្រូវនឹងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ០១២ ៨៥ ២០ ៨៦/ ០១២ ៨៤ ៨៥ ២១)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៤:៣០នាទីរសៀល **ថ្ងៃចន្ទ ១៣ រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២** ត្រូវនឹងថ្ងៃថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង**១៤:៣០** **នាទីរសៀល ថ្ងៃចន្ទ ១៣ រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២** ត្រូវនឹងថ្ងៃថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងអង្គភាពលទ្ធកម្មគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៩

**ប្រធានអគ្គនាយក**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

សុខ ឫទ្ធី

<u>ចម្លងជូនៈ</u>
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ